ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខៈ ..១០០០......PC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការផ្គត់ផ្គង់ Accessories & Spare Parts ចំនួន ១០ មុខ (កញ្ចប់ទី១៧) សម្រាប់គម្រោងការងារបន្តចរន្ត ជួសជុល ថែទាំ និងកែលម្អបណ្តាញ របស់អគ្គិសនីខេត្តចំនួន ០៨ (ផែនការឆ្នាំ២០២៣)

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ Accessories & Spare Parts ចំនួន ១០ មុខ (កញ្ចប់ទី១៧) សម្រាប់គម្រោងការងារបន្តចរន្ត ជួសជុល ថែទាំ និងកែលម្អបណ្តាញ របស់អគ្គិសនីខេត្តចំនួន ០៨ (ផែនការឆ្នាំ២០២៣) ។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋានៈ អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពីថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២៤ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 092 652 357 និង Website: www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៤:00 ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២៤ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង ១៥:00 ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២៤ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ...... ខែ...... ឆ្នាំ ថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤
ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហាន់_ទូច

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ